# កិច្ចសំភាសន៍របស់ម៉ាឈ្មោះ ចែប សុគន់

កៈ អ្នកសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ ចែប សុគន់

កៈ ជាដំបូងខ្ញុំសូមជំរាបសួរម៉ា!

ខៈ ចាស!

កៈ ចាសម៉ាថ្ងៃនេះខ្ញុំមានឪកាសដែលបានសំភាសន៍ម៉ាផ្ទាល់ទាក់ទងនឹងជាមួយនឹងប្រវត្តិរបស់ម៉ាហើយនឹងជីវិតរបស់ម៉ាដែលម៉ាធ្លាប់បានតស៊ូតាំងពីក្មេងរហូតមកដល់ឥលូវ ក៏ដូចជាសម័យមុនក្នុងជំនាន់ពលពតអីចឹងណាស់ម៉ា ម៉ាមានជីវិតតស៊ូនឹងបទពិសោធន៍ជាច្រើនដើម្បីចែកចាយអោយទៅដល់ក្មេងៗ(សំលេងកូនក្មេងយំ) ក្រោយគេបានស្ដាប់ចឹងថ្ងៃនេះខ្ញុំនឹងធ្វើការសំភាសន៍ម៉ាទាក់ទងជាមួយនឹងអឺ....ជីវិតរបស់ម៉ាហើយនឹងប្រវត្តិរបស់ម៉ានឹងដើម្បីនឹងយកទៅរក្សាទុកអោយបានដល់កូនចៅជំនាន់ក្រោយនឹងអោយពួកគាត់បានស្ដាប់ហើយនឹងយើងនឹងយកសំលេងរបស់ម៉ានឹងយកទៅដាក់នៅក្នុងវេបសាយរបស់សាលានៅខាងសហរដ្ឋអាមេរិច ចាសហើយចឹងតើម៉ាអនុញ្ញាតអោយខ្ញុំបានធ្វើការសំភាសន៍ម៉ាដែរឬទេ?

ខៈ អោយសំភាសន៍បើតាមការដែលលំបាកនឹងលំបាកច្រើនយ៉ាងណាស់កូនអើយធ្វើការងារមិនស្គាល់យប់មិនស្គាល់ថ្ងៃណាស់បើគេប្រើអោយយើងធ្វើអីយើងចេះតែធ្វើទៅសង្គមនេះយើងបើមិនធ្វើមិនដើរតាមគេវាមិនកើតទេ(សំលេងកូនក្មេងពីខាងក្រៅ)ទាល់តែយើងនឹងទៅតាមគេចឹងទៅអោយតែជីវិតនឹងបានរស់គេអោយធ្វើអីក៏ធ្វើទៅ(សំលេងរំខានពីខាងក្រៅ)!

កៈ ចាសៗម៉ា ចឹងអឺ.... មុននឹងចូលទៅដល់បទពិសោធន៍នៃជីវិតរបស់ម៉ាចឹងខ្ញុំសូមធ្វើការអនុញ្ញានសួរឈ្មោះរបស់ម៉ាជាមុនសិនម៉ាមានឈ្មោះអីដែរ?

ខៈ ខ្ញុំឈ្មោះចែប សុគន់(សំលេងកូនក្មេង)!

កៈ ចាសម៉ា ហើយចុះឈ្មោះរបស់ម៉ាមានឈ្មោះហៅក្រៅដែរឬទេម៉ា?

ខៈ អត់មានទេឈ្មោះតែចឹងនឹងឈ្មោះ គន់!

កៈ ចាសហើយចុះចំណែកឈ្មោះនៅក្នុងអត្តសញ្ញាណប័ណ្ណវិញម៉ា?

ខៈ ចែប សុគន់!

កៈ ចាសហើយអឺ....សព្វថ្ងៃអាយុប៉ុន្មានឆ្នាំហើយ?

ខៈ ខ្ញុំសព្វថ្ងៃអាយុ៧៨ឆ្នាំហើយ(សំលេងកូនក្មេងពីខាងក្រៅរំខាន)!

កៈ ចាសម៉ា ម៉ាមាននៅចាំថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនដែរឬទេ?

ខៈ ហើយខ្ញុំមិនចាំសោះហើយចៅ(សំលេងរំខានពីខាងក្រៅ)!

កៈ ចុះថ្ងៃខែឆ្នាំកំណើតរបស់ម៉ាជាខ្មែរយើងដូចជាចន្ទគតិ
សរិយគតិអីនឹងម៉ាមាននៅចាំដែរឬទេម៉ា?

ខៈ អត់ចាំទាំងអស់!

កៈ ចាសហើយចុះក្រុមគ្រួសាររបស់ម៉ាអឺ...ឪពុកម្តាយរបស់ម៉ាមានឈ្មោះអីដែរ?

ខៈ គាត់ឈ្មោះចែបនឹង!

កៈ ពួកគាត់មានឈ្មោះអីខ្លះទៅម៉ា?

ខៈ គាត់ឈ្មោះ ប៉ាន់ ចែប!

កៈ ចុះឪពុកវិញ?

ខៈ ឪពុកឈ្មោះចែប ហើយម្តាយឈ្មោះលីកែស!

កៈ ពួកគាត់មានកូនប៉ុន្មាននាក់ដែរម៉ា(សំលេងរំខានពីខាងក្រៅ)?

ខៈ កូនមិនមានប៉ុន្មានទេ....

ក៖ អញ្ចឹងអី....

ខ៖ ដឹងតែសព្វថ្ងៃនឹងនៅរស់បួននាក់!

ក៖ ចាសម៉ាពួកគាត់ជាបងប្អូនរបស់ម៉ាទាំងអស់ន៏ម៉ាន៏?

ខ៖ ចាស!

ក៖ ចាសម៉ា ហើយចុះពួកគាត់មានឈ្មោះអីគេខ្លះម៉ាមាននៅចាំដែរឬទេ?

ខ៖ ឈ្មោះបងប្អូនរបស់ខ្ញុំក៏អីនាង?

ក៖
ចាសឈ្មោះបងប្អូនរបស់ម៉ាទាំងអស់ដែលត្រូវជាបងប្អូនបង្កើតម៉ាណាស់ម៉ា(សំលេងរំខានពីខាងក្រៅ)ពួកគាត់មានឈ្មោះអីខ្លះទៅ?

ខ៖ អូ...ឈ្មោះយាយ យឿន ហើយឈ្មោះ យឿន ហើយឈ្មោះវ៉ាន់(សំលេងរំខានពីខាងក្រៅ)!

ក៖ ចឹងសរុបទាំងអស់បួននាក់ន៏អ៊ុំ?

ខ៖ នឹងហើយចាស ទាំងអស់បួននាក់គឺថា បួននាក់ខ្ញុំ
បងប្អូនរបស់ខ្ញុំបួននាក់នឹង(សំលេងរំខានពីខាងក្រៅ)!

ក៖
អូ....ហើយអឺ....ម៉ាបងប្អូនរបស់ម៉ាសព្វថ្ងៃនៅមានជីវិតដែរឬទេម៉ា(មានសំលេងរំខានពីខាងក្រៅ?

ខ៖ នៅទាំងអស់នឹង(សំលេងកូនក្មេងពីខាងក្រៅ)!

ក៖ ចាសហើយម៉ាជាកូនទីប៉ុន្មានដែរ?

ខ៖ ខ្ញុំជាកូនទីមួយ!

ក៖ បងគេន៏ម៉ា?

ខ៖ ចាស(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាសហើយពួកគាត់ទាំងអស់គ្នាមានទីលំនៅៗឆ្ងាយពីគ្នាឬក៏នៅជិតៗនេះដែរម៉ា?

ខ៖ នៅជិតនឹងតើទាំងអស់គ្នានឹង!

ក៖ ទាំងអស់ទាំងប្អូនម៉ងម៉ា?

ខ៖ ចាសនៅខាងណោះក៏ប្អូន នៅខាងនោះក៏ប្អូននៅជិតគ្នានឹង!

ក៖ ចាស ចឹងស្រួលហើយបាននៅជិតៗគ្នាចឹងយើងអឺ...ងាយស្រួលចែកគ្នាពេលទៅណាទៅណីអីដឹងស្រួលបបួលគ្នាទៅ!

ខ៖ (សើច)!

ក៖ ចាសហើយម៉ាពួកគាត់ទាំងអស់គ្នាស្រីប៉ុន្មានប្រុសប៉ុន្មានដែរម៉ា?

ខ៖ ស្រីបី ប្រុសតែមួយទេ!

ក៖ ប្រុសតែមួយទេហ៎ម៉ា ប្រុសចុងក្រោយគេ ប្រុសពៅគេហ៎ម៉ា?

ខ៖ អត់ទេពៅស្រី(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាសតើកូនប្រុសត្រូវជាប្អូនរបស់ម៉ានឹងគាត់មានឈ្មោះអីគេដែរម៉ា?

ខ៖ គាត់ឈ្មោះ ឃឿន!

ក៖ ចាសលោកពូឃឿន ចាសហើយសព្វថ្ងៃនឹងពួកគាត់មានគ្រួសារមានប្តីប្រពន្ធមានកូនមានចៅអស់ហើយន៏ម៉ា?

ខ៖ មានអស់ហើយ!

ក៖ ចាសហើយពួកគាត់ទាំងអស់គ្នានឹងនៅជិតៗនេះទេ ហើយពួកគាត់ទាំងអស់គ្នានឹងប្រកបមុខរបរអីខ្លះទៅម៉ា?

ខ៖ អឹម...តែត្បាញនឹងចៅអើយត្បាញ!

កៈ ត្បាញន៍ម៉ា!

ខៈ ជីវភាពនឹងរស់នៅវេទនាដែរនឹងមិនត្រឹមត្បាញនឹងទេ!

កៈ ចាសហើយចុះចំណែកម៉ាសព្វថ្ងៃម៉ាក្របកមុខរបរអីដែរម៉ា?

ខៈ ហើយខ្ញុំអត់មានរកស៊ីមុខរបរអីទេតែកូននឹងរកស៊ីចិញ្ចឹមម៉ែចិញ្ចឹមឪទៅ
ខ្ញុំនៅតែកូនមិញនឹងមួយនឹងទេនៅជាមួយវាមិញនឹងណាស់!

កៈ ចាសចុះសព្វថ្ងៃម៉ាមានកូនប៉ុន្មាននាក់ដែរម៉ា?

ខៈ ខ្ញុំមិនដឹងកូនប៉ុន្មានទេ....កូនទាំងអស់ប្រាំមួយនាក់(សំលេងរំខានពីខាងក្រៅ)!

កៈ ពួកគាត់ឈ្មោះអីខ្លះ.....

ខៈ
ប៉ុន្តែគេមានគ្រួសារអស់ហើយទៅនៅឆ្ងាយៗណាស់នៅជិតតែវាមួយនឹងទេហើយនឹងកូនក្រោយនឹងមួយទេ!

កៈ ចាសៗម៉ាហើយអឺ....តើម៉ាកូនៗរបស់ម៉ាទាំងអស់គ្នានឹងពួកគាត់មានឈ្មោះអីខ្លះទៅម៉ា?

ខៈ មានឈ្មោះភៀង ឃើន ឈ្មោះសារុំ ឈ្មោះសារី ទាំងគ្នាបួននាក់នឹង!

កៈ ចាសៗកូនទាំងបួននាក់ ហើយទាំងអស់៦នាក់ហើម៉ា?

ខៈ ចាសទាំងគ្នានឹង៦នាក់!

កៈ ចាសម៉ា!

ខៈ ប៉ុន្តែកូនប្រុសៗនឹងគេនៅឆ្ងាយ!

កៈ ចាស!

ខៈ កូនស្រីៗនឹងបាននៅជិតម្តាយ!

កៈ ចាស ចុះសព្វថ្ងៃកូនដែលនៅជាមួយនឹងម៉ាមានប៉ុន្មាននាក់ដែរម៉ា?

ខ៖ មាន១បីនាក់
ប្ដីនឹងមុខរបររត់ឌុបម៉ូតូនឹងណាស់ទុកគ្រាន់ចិញ្ចឹមជីវិតនឹងទៅពិបាកណាស់នាងអើយ(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាស!

ខ៖ រកមួយថ្ងៃនហូបមួយថ្ងៃយ៉ាងនេះ
បើពឹងទៅលើគ្នាតែមួយម្នាក់ឯងរកស៊ីចិញ្ចឹមម៉ែចិញ្ចឹមកូន!

ក៖ ចាសម៉ា ហើយពួកគាត់រៀបការអស់ហើយន៏ម៉ា?

ខ៖ ចាសកូនរបស់ខ្ញុំនឹងរៀបការមានគ្រួសារអស់ហើយ!

ក៖ ចាសម៉ា ហើយអឺ....ម៉ាកូនរបស់ម៉ាស្រីប៉ុន្មានប្រុសប៉ុន្មានដែរ?

ខ៖ កូនរបស់ខ្ញុំនឹងស្រីបួនហើយប្រុសតែពីរទេ!

ក៖ ស្រីបួនហើយប្រុសតែពីរទេ ចាសហើយម៉ាមានកូនចៅចៅទួតហើយន៏ម៉ា?

ខ៖ ចាស?

ក៖ ចាសម៉ា ហើយចុះម៉ាមានចៅទួតហើយឬនៅម៉ា?

ខ៖ មានចៅទួតហើយមានបួនប្រាំអ្នកហើយចៅទួតហ៎ចៅច្រើនណាស់ខ្ញុំ(សើច)!

ក៖ ចាសម៉ា!

ខ៖ ប៉ុន្តែពួកគេទាំងអស់គ្នានឹងនៅឆ្ងាយនៅឯខេត្តពោធិ៏សាត់ឯណាណោះទៅ!

ក៖ ហើយទៅយូរ១បានគេមកលេងម្ដងហ៎ម៉ា?

ខ៖ ចាស យូរ១គេមកលេងនឹងខ្ញុំម្ដងមួយឆ្នាំគេមកលេងម្ដងពីរដងចឹងទៅណាស់ចៅ!

ក៖ ចាសចឹងចៅ១របស់ម៉ាគឺគួរអោយស្រលាញ់ចាស
ហើយពួកគាត់មកលេងជាមួយនឹងម៉ារាល់ថ្ងៃឬក៏យូរមកលេងម្ដងម៉ា?

ខ៖ យូរៗមកលេងម្តងនឹងចៅគេអាឡើយរវល់រកស៊ីចឹងណាស់(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាសម៉ា ហើយអឺ....ម៉ាដែលធ្លាប់ទៅលេងនឹងពូកគាត់ដែរឬទេ?

ខ៖ អត់ទេ ខ្ញុំអត់ដែលបានទៅទេចៅ(សើច)!

ក៖ ចាសម៉ា ម៉េចចឹងម៉ា?

ខ៖
អួយ....ខ្ញុំអត់ស្រួលខ្លួនខ្ញុំទេសព្វថ្ងៃនឹងនោះវិលវល់នៅក្នុងខ្លួនណាស់ធ្វើដំណើរទៅឆ្ងាយមិនបានទេចៅ!

ក៖ ចាសម៉ាហើយចុះសព្វថ្ងៃម៉ាមានជំងឺអីដែរម៉ាឈឺអីគេដែរ?

ខ៖
មានតែលើសឈាមទៅចេះតែវិលទៅជូនណាទៅក្រពះពោះវៀនចឹងទៅ(សំលេងរំខានពីខាងក្រៅ)!

ក៖ ចុះពេទ្យគេថាម៉េចដែរម៉ា ជំងឺរបស់ម៉ាអាចនឹង.....

ខ៖ មិនដឹងគេថាម៉េចទេ
មើលទៅគេចេះតែថាជួបខ្លាញ់ជួបស្អីឯណាឯណីច្រើនណាស់(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាសម៉ា!

ខ៖ (សំលេងកូនក្មេង)ជូនទៅទឹកថ្នាំគេយកមកលក់ផឹកទៅក៏វាមិនឃើញជាបាត់ទៅណាដែរ!

ក៖ ចាសម៉ា ហើយម៉ាអឺ....ទីលំនៅសព្វថ្ងៃម៉ាមានទីលំនៅៗឯណាដែរម៉ា?

ខ៖ នឹងនៅនឹងៗ!

ក៖ ទីលំនៅរបស់ម៉ាដែលម៉ាកំពុងរស់នៅសូមម៉ាជួយបញ្ជាក់ភូមិឃុំ សង្កាត់
ហើយនឹងខេត្តផងម៉ា ភូមិអីដែរម៉ា?

ខ៖ ខ្ញុំហ្អែស? ខ្ញុំនៅភូមិពក ក្នុងខេត្តកណ្តាល!

កៈ ចាសម៉ា នៅស្រុកណា....

ខៈ ហើយនៅនឹងឃុំកោះឧញ៉ាតី!

កៈ នៅកោះឧញ៉ាតី ចាស ហើយម៉ាមានទីកន្លែងកំណើតរបស់ម៉ាម៉ងនៅឯណាដែរម៉ា?

ខៈ អឺម! ស្រុកកំណើតរបស់ខ្ញុំនៅនឹងៗម៉ង(សំលេងរំខានពីខាងក្រៅ)!

កៈ អូ...ចឹងម៉ាមិនដែលបានផ្លាស់ទីលំនៅទេន៏ម៉ា?

ខៈ អត់ដែលទេថៅ!

កៈ ចាស(សំលេងរំខានពីខាងក្រៅ)!

ខៈ តាំងពីរួចអាពតមកនៅតែនឹងៗ!

កៈ ចាសម៉ា ចឹងកាលនៅជំនាន់ពលពតនឹងគេអត់មានបានផ្លាស់ម៉ាទៅណាទេន៏ម៉ាន៏?

ខៈ អត់ទេ គេមិនបានផ្លាស់ប្ដូរអោយខ្ញុំទៅនៅ
ឯណាទេព្រោះអីកាលនឹងខ្ញុំជាប់កូនខ្ចី(ម៉ាមានកូនតូច)!

កៈ ចាសម៉ា ហើយកាលនឹងគេអត់មានថាជំលៀសម៉ាទៅណាទៅណីអត់មានទេ?

ខៈ អត់ទេ
គេជំលៀសតែ....តែម៉ែឪរបស់ខ្ញុំទៅទេពួកគាត់នឹងត្រូវបានគេជំលៀសយកទៅអស់....

កៈ អូ...គេជំលៀសទៅណាដែរម៉ា?

ខៈ
ហើយនឹងបងប្អូនរបស់ខ្ញុំអីនឹងគេយកទៅអស់ហើយនៅតែខ្ញុំម្នាក់ឯងនឹងទេ(សំលេងសត្វយំ)!

កៈ គេជំលៀសអឺ....ឪពុកម្ដាយបងប្អូនរបស់ម៉ានឹងយកពួកគាត់ទៅនៅខាងណាដែរម៉ា?

ខៈ អឺម...កាលនឹងមិនដឹងថាទៅខាងណាមកខាងណីទេ(សំលេងសត្វយំ) ខ្ញុំមិនដឹងដែរថៅ!

កៈ អឺម.....

ខ៖ គេជំលៀសទៅឆ្ងាយណាស់ទៅខាងភូមិអន្លង់ៗបឹងកាចាប់!

ក៖ ចាសម៉ា
ហើយអឺ....ពួកគាត់នៅពេលដែលគេជំលៀសហើយពួកគាត់ត្រឡប់មកវិញដែរឬទេម៉ា?

ខ៖ ពួកគាត់ត្រឡប់មកវិញអស់ហើយ!

ក៖ ពួកគាត់ត្រឡប់មកវិញ ជុំគ្នាអស់ហើយន៏ម៉ាន៏?

ខ៖ ចាសត្រឡប់មកវិញ ជួបជុំគ្នាវិញអស់ហើយ!

ក៖ ចាសម៉ា
ចឹងម៉ាមិនមានបងប្អូនឬក៏សាច់ញាតិរបស់ម៉ាណាមួយបានស្លាប់នៅក្នុងជំនាន់ពលពតនោះទេ
?

ខ៖
អឹម....ស្លាប់អស់ច្រើនណាស់មួយកូនមួយចៅរបស់ខ្ញុំទៅអស់មួយពូជ(កូនចៅរបស់ម៉ាស្លាប់អស់ច្រើន) នៅតែ(សំលេងរំខានពីខាងក្រៅ) មួយពូជនឹងនៅតែមួយទេ
ត្រឡប់មកស្រុកវិញនឹង(សំលេងមនុស្សស្រីនិយាយគ្នា)!

ក៖
អូ....គាត់ស្លាប់ដោយសារអីដែរម៉ាដោយសារតែគេយកគាត់ទៅសំលាប់ឬក៏គេជំលៀសគាត់ទៅហើយបាត់ដំណឹង(សំលេងកូនក្មេង)?

ខ៖ គេជំលៀសយើងទៅនឹងដូចថាណាយើងវាមានជំងឺឈឺស្កាត់ផង
ណាយើងវាអត់មានអីសំរាប់ហូបផង
(សំលេងរំខានពីខាងក្រៅ)កូនចៅទៅទាំងប៉ុន្មានងាប់អស់នៅតែកូនមួយត្រឡប់មកវិញ!

ក៖ អូយម៉ា! ចាស ចឹងហើយម៉ាកាលនឹងនៅក្នុងជំនាន់ពលពតម៉ាមានអាយុប៉ុន្មានឆ្នាំដែរ?

ខ៖ (សំលេងរំខានពីខាងក្រៅ) អឹម....ខ្ញុំកាលនឹងអាយុចូលៗ៩០ហើយ
៩១ឆ្នាំហើយយ៉ាង(ម៉ាកាលសម័យនោះមានអាយុប្រហែលជា៩១ឆ្នាំ)!

កៈ
ចាសម៉ាចឹងហើយកាលនឹងគេប្រើម៉ាអោយធ្វើអីគេខ្លះដែរកាលជំនាន់ពលពតនឹងណាស់ម៉ា?

ខៈ ចាស?

កៈ កាលជំនាន់ពលពតនឹងគេបានប្រើម៉ាអោយធ្វើការងារអ្វីខ្លះដែរ?

ខៈ អូ...ខ្ញុំហ្អែស? គេគ្រាន់តែខ្ញុំដូចថាដាំពោត ដាំដំឡូវ ដាំត្រាវអីចឹងទៅ
បន្លែរបង្ការគ្រាន់ទុកធ្វើម្ហូបនឹងណាស់វាអីទេ
គេអត់មានធ្វើទុក្ខធ្វើទោសអីទេ(សំលេងរំខានពីខាងក្រៅ)គ្រាន់តែថាវាអត់ឃ្លានទាំងយើងទាំង
គេចឹងណាស់ហើយគេប្រើអោយធ្វើអីយើងចេះតែធ្វើនឹងទៅអត់ហ៊ានទៅតវ៉ាអីនឹងគេទេ
អាណិតតែកូនខ្ញុំកូនគេវាអត់ឃ្លានដូចតែគ្នានឹងណាស់ហើយត្រង់ថាគេធ្វើទោសអីនឹងអត់ទេបើ
គេប្រើអោយធ្វើអីក៏យើងធ្វើតាមតែគេប្រាប់នឹងទៅណាស់បើថាគេយកយើងទៅវ៉ៃចោលអីអត់
ទេ(សំលេងរំខានពីខាងក្រៅ)!

កៈ ចាសម៉ា
ហើយនៅពេលនឹងម៉ាធ្វើការនឹងម៉ាគិតថាវាធ្វើអោយពិបាកខ្លាំងដល់ថ្នាក់ណាដែលម៉ា
ដែលវាធ្វើអោយម៉ាចងចាំមិនអាចនឹងបំភ្លេចបានឡើយណាស់ម៉ា?

ខៈ
ចងចាំនឹងយើងចេះតែចងចាំហើយបើយើងមិនធ្វើទៅតាមគេទេគេផ្តាច់របបយើងហើយយើង
បានអីសំរាប់ហូបចឹងហើយចេះតែធ្វើទៅអោយតែបានបបរនឹងហូបកុំអោយអត់បានអត់ទឹក
ហើយ(សំលេងរញ៉េរញ៉ៃពីខាងក្រៅ) គេប្រើដូចគេដូចក្របីយ៉ាងនេះ(សំលេងកូនក្មេងស្រែក)!

កៈ ចាសម៉ា
ចុះពេលនឹងអឺ....គេប្រើអោយម៉ាទៅធ្វើអីគេខ្លះដែលម៉ាគិតម៉ាចងចាំថាហើយវាពិបាកខ្លាំងណា
ស់ដែលធ្វើអោយម៉ាមិនអាចនឹងបំភ្លេចបានសោះឡើយនៅក្នុងមួយជីវិតរបស់ម៉ានឹងណាស់ម៉ា
ព្រោះដោយសារតែវាពិបាកខ្លាំងពេកចឹងណាស់ហើយចឹងម៉ាគិតថាមានការងារអីគេខ្លះដែល
លំបាកនឹងមានអីគេខ្លះ?

ខៈ អឹម!

កៈ ចាស ចឹងម៉ាគិតថាមានការងារអីគេខ្លះដែលគេប្រើម៉ានឹងមានអីគេខ្លះ?

ខ៖ មានតែទៅស្ទូងទៅដកនឹងប៉ុន្តែយើងវាមិនចេះកាលនឹងទៅស្ទូងនឹងទៅឯខាងព្រៃកហ្លួងឯណោះទៅជិតបឹងប្រាទៅនៅនឹងៗទៅដេកនៅក្នុងព្រៃក្នុងផ្សៃនៅនឹង
មានឈ្លើងមានអីលោកៈអើយត្រីឆ្អាម(សំលេងរំខានពីខាងក្រៅ)
ចឹងបានថាមិនភ្លេចទេនៅតែចាំចឹងបានថាបណ្តាំចៅបណ្តាំកូនអោយកូនរកអីកុំអោយពិបាកដល់ខ្លួនចឹងណាស់បើបានស្រុកទេសបានសុខបានស្រួលចឹងទៅយើងចេះតែខិតខំរកចិញ្ចឹមជីវិតទៅខ្លួនយើងវាមិនពិបាកប៉ុន្មានទេបើគេបើយើងបានដឹងថាវាពិបាកប៉ុនណា
ប៉ុន្មានជំនាន់មកហើយពីរបីជំនាន់មកហើយតាំងពីខ្ញុំដឹងក្តីមកប្រវត្តិរបស់ខ្ញុំមានភាពជូរច៉ត់ខ្លាងណាស់!

ក៖ ចាសម៉ា ហើយចឹង....

គ៖ ហេ! យាយគន្ធ(សំលេងកូនក្មេងស្រែកហៅម៉ា)?

ខ៖ ចាសម៉ា!

ក៖ ចាសម៉ា ចឹងដល់ពេលហើយម៉ាកាល
នឹងនៅអឺ....ជំនាន់ពលពតនឹងម៉ាបានរបបអីគេដើម្បីទទួលទានប្រចាំថ្ងៃ?

ខ៖
ប្រចាំថ្ងៃគេដាំបាយអោយយើងហូបនៅ....ទៅការដ្ឋានទៅអោយយើងទៅហូបមួយកន្លែងចឹងណាស់គេអត់អោយយើងទៅហូបនៅឯផ្ទះរបស់យើងរៀងៗខ្លួនទេគេអោយបបរយើងហូបទៅជូនណាទៅក៏បានហូបបាយចឹងទៅ
ជូនណាទៅបបរទៅលាយដំឡូងទៅលាយពោតចឹងយើងហូបហើយទៅយើងចេះតែហូបចឹងទៅគេចេះតែរកនឹកឃើញធ្វើអោយតែរួចៗទៅ!

ក៖ ចាសម៉ា!

ខ៖
បានថាពិបាកអើយសែនពិបាកលោកអើយនៅកាលជំនាន់នឹងនោះ(មានសំលេងរំខានពីខាងក្រៅ)!

កៈ
អឺម....ម៉ាហើយចឹងអឺ....គេបានប្រើម៉ាហើយម៉ាពិបាកខ្លាំងណាស់អឺ...គេអោយបាយម៉ាញុំដែរឬក៏មានតែបបរកាលនឹងម៉ា?

ខៈ មានបាយពីណាមកមានតែបបរនឹងឯងចៅ....

កៈ ចឹងហ៎ មិញខ្ញុំលឺម៉ាថាមានបាយដែរ!

ខៈ បើបាយនឹងគេដាំបាយលាយដំឡូង
អញ្ចឹងតៅទៀតណាស់ពេលខ្លះទៅក៏លាយនឹងពោតចឹងទៅ គេមិនបានអោយ
បាយយើងហូបនឹងបានស្រួលបួលម្តងណាទេព្រះអង្គអើយ(មានសំលេងរំខានពីខាងក្រៅ)
ហើយយើងម៉េចនឹងហ៊ានទៅថាយ៉ាងម៉េចអោយគេលោកមិនហ៊ានថាអីទេគេបញ្ជារយ៉ាងម៉េចធ្វើចឹង!

កៈ (មានសំលេងរំខានពីខាងក្រៅ)
ហើយបបរគេមានអោយម៉ាហូបអីខ្លះម៉ាមានចាំមុខម្ហូបនៅក្នុងជំនាន់នឹងដែរឬទេ?

ខៈ អឺម.....មុខម្ហូបនោះស្ងោរផ្អកជាមួយនឹង....ស្ងោរផ្អកជាមួយនឹងផ្លែទ្រព ស្លម្ជូរទៅស្លអីចឹងហូបជាមួយនឹងបបរទៀតណាមិនមែនបាយទេ!

កៈ អឺម!

ខៈ បានថាប្រវត្តិកាលជំនាន់របស់ម៉ានឹងវាជូរចត់ណាស់ចៅមិនមែនស្រួលដូចសព្វថ្ងៃនឹងទេ!

កៈ ចាសម៉ា ហើយបបរនឹងអោយម៉ាមួយថ្ងៃប៉ុន្មានពេលប៉ុន្មានដងដែរ?

ខៈ អឺម....តែពីរដងនឹងព្រឹកនឹងល្ងាចនឹង តែថ្ងៃមិនមែនដូចធ្វើបាយថ្ងៃត្រង់
យកពេលព្រឹកនឹងទៅធ្វើជាបាយថ្ងៃត្រង់នឹងម្តង ហើយល្ងាចនឹងម្តង!

កៈ អឺម....ចាសម៉ាហើ
យម៉ានៅពេលដែលគេអោយម៉ាហូបមួយថ្ងៃតែពីរដងចឹងតើម៉ាហូបបានឆ្អែតដែរឬទេម៉ា?
ព្រោះរាល់ដងម៉ាធ្លាប់ពិសារបីដងម៉ាត្រូវហ្អែសម៉ា?

ខៈ ចាសរាល់ថ្ងៃយើងហូបបីដងក្នុងមួយថ្ងៃណាស់នឹងចៅ!

កៈ (សើច)!

ខៈ មិនដឹងធ្វើម៉េចហ៎ បើគេដូសអោយយើងហូបតែប៉ុ
នឹ្ងយើងមានតែហូបតែប៉ុនឹ្ងទៅចេះតែទ្រាំអត់ទ្រាំឃ្លានចឹងទៅណាស់ថៅធ្វើម៉េចបើយើងកើ
តមកចំកាលៈទេសៈដំណាក់កាលចឹងនឹងហើយយើងមានតែចេះតែទ្រាំទៅអោយតែបានរស់
មានជីវិតទៅ!

កៈ ចាសម៉ា
ហើយចឹងម៉ានៅពេលដែលម៉ាហូបមិនគ្រប់គ្រាន់ចឹងពេលនឹងម៉ាមានដែលធ្លាប់ទៅលួចគេហូប
ដែរឬទេនៅពេលនឹង?

ខៈ ខ្ញុំអត់មានទេអត់ដែលមានលួចអីគេទេថៅអើយ!

កៈ ចាសចឹងកាលនឹងម៉ាអត់ដែលមានធ្លាប់លួចគេយកមកពិសារទេហ៎ម៉ា?

ខៈ អត់ទេខ្ញុំខ្លាចណាស់ថៅ ខ្ញុំខ្លាចណាស់ខ្ញុំ ចឹងបានជាពួកគេនឹងថា
ពួកខ្ញុំបើថាទៅនៅក្រៅស្រុកក្រៅទេសនឹងមិនស្គាល់ច្បាស់ជាស្លាប់អស់ហើយបើអត់ហ៊ានអញ្ចឹ
ងនោះ យើងអត់ហ៊ានទៅលួចអីគេទេ
តែបើរបស់យើងនឹងដូចយើងមានដាំជាចេកដាំអីនឹងគ្រាន់បានហ៊ានកាប់អីខ្លះទៅ
យកទៅស្ងោរអីចឹងទៅណាស់ទុកគ្រាន់យើងបានហូបខ្លះចឹងទៅ
បើថាទៅខាងក្រៅៗនឹងអត់ហ៊ានសោះតែម៉ង!

កៈ (សំលេងរំខានពីខាងក្រៅ) ចាសត្រូវហើយម៉ា
កាលជំនាន់នឹងគេតឹងតែងរឿងញុំគេអត់អោយដូចថាអឺ....

ខៈ គេមិនអោយយើងចេះតែញុំផ្តេសផ្តាសទេលោកហ៊ើយ គេក្រឹតក្រមជាងអីទៅទៀតនឹង
ដើរទៅដល់កន្លែងហូបបាយនឹងសឹងតែថាដើរវាមិនដល់ទេកន្លែងបាយនឹងវាឆ្ងាយពីកន្លែងធ្វើ
ការ(សំលេងរំខានពីខាងក្រៅ)!

កៈ ចាសម៉ា!

ខៈ ចាសហើយនិយាយពីប្រវត្តិរបស់ខ្ញុំនឹងវាពិបាកខ្លាំងណាស់ចឹងណាស់ថៅអើយ!

កៈ ចាសៗម៉ា
ហើយម៉ាដល់ពេលហើយបន្ទាប់មកទៀតម៉ាបាន...នៅកាលជំនាន់ពលពតចឹងម៉ាធ្លាប់បបានឆ្លងកាត់ពិសោធន៍ចឹងម៉ាដឹងថានៅជំនាន់នឹងវាលំបាកអីចឹង
ម៉ាគិតថាចង់អោយរួចផុតពីជំនាន់នឹងអោយបានឆាប់ៗដែរឬទេ?

ខៈ (សំលេងរំខានពីខាងក្រៅ) អឹម....និយាយមិនចង់ម៉េចលោកអើយ
ទន្ទឹងអើយទន្ទឹងគ្រាន់តែប៉ុន្មាននឹងដូចជាយូរអើយសែនយូរ(សំលេងរញ៉េរញ៉ៃពីខាងក្រៅ)
គ្រាន់តែប៉ុន្មានឆ្នាំសោះនឹង ទន្ទឹងអោយតែឆាប់រួចឆាប់ផុត
ជូនណាទៅបែកកូនបែកបងបែកប្អូនអស់រលីង
ខ្ញុំនៅតែខ្ញុំតើបែកបងបែកប្អូនម៉ែឪអស់រលីងនៅតែម្នាក់ឯង!

កៈ ចាសម៉ា
ហើយដល់ពេលអញ្ចឹងហើយកាលដែលនៅក្នុងជំនាន់ពលពតនឹងម៉ាដែលត្រូវបានគេធ្វើបាបដែរឬទេម៉ា?

ខៈ អត់អីទេខ្ញុំ គេអត់មានធ្វើបាបអីខ្ញុំទេ
ព្រោះគ្រួសាររបស់ខ្ញុំស្លូតណាស់ខ្លាចគេណាស់គេថាអោយធ្វើអីនឹងហើយមិនទៅហ៊ានលួចហ៊ានវះអីគេទេមានប៉ុន្មានហូបប៉ុន្នឹងទៅចេះតែរទ្រាំអត់ទៅដើររវេនរវ័ន្តនឹងចង់ដួលយ៉ាងនេះ
ចេះតែទ្រាំទៅអោយតែបានរស់កុំតែគេធ្វើទុក្ខបុកម្នេញយើងទៅបានហើយ
រឿងហូបចុករឿងអត់បានតែបើគេវ៉ៃធ្វើបាបខ្ញុំអត់ទេអត់មានគេវ៉ៃទេ!

កៈ ចាសម៉ា
ហើយនៅពេលនឹងម៉ាធ្លាប់ឈឺដែរឬទេនៅក្នុងជំនាន់ពលពតនឹងបើម៉ាញុំ...ពិសារអីអត់គ្រប់គ្រាន់ចឹងបើគេអោយម៉ាហូបតែបបរម៉ាពិសារហើយតែពីរពេលទៀតចឹងណាស់ម៉ា?

ខៈ ឈឺដែរតើ!
ហើយពេលដែលឈឺចឹងដើរបេះស្លឹកឈើស្លឹកព្រៃផឹកទៅស្លឹងត្រួយទៀបត្រួយអីនឹងចេះតែហូបទៅក្តៅខ្លួនក្តៅអីស្លឹកទៀបស្លឹកអីនឹងមានថ្នាំពេទ្យថ្នាំអីរបស់គេដែរតើពប៉ុន្តែយើងចង់ជាយើងបេះតែស្លឹកទៀបយកមកច្របាច់ផឹកទៅអោយវាបានត្រជាក់ខ្លួនទៅណាស់ចៅ!

កៈ ចាសម៉ា ចឹងនៅក្នុងពេលនឹងម៉ាអត់មានបានឈឺអីក្រៅដូចថាអោយខ្លាំងធ្ងន់ធ្ងរទេ
គឺម៉ាគ្រាន់តែថាឈឺជំងឺលក្ខណៈថាជំងឺតិចតួចៗ?

ខ៖ ចាសកាលនឹងឈឺជំងឺតិចតួចទេ អត់មានខ្លាំងទេ!

ក៖ ចាសម៉ា
ហើយនៅពេលដែលគេប្រើម៉ានៅចំពេលដែលម៉ាឈឺនឹងគេនៅតែប្រើអោយម៉ាធ្វើការចឹងឬក៏គេបានអោយម៉ានឹងឈប់សំរាកពីធ្វើការដែរម៉ា?

ខ៖
គេបានអោយយើងសំរាកដែរបើយើងទៅមិនរួចទេយើងឈប់សំរាកមួយព្រឹកអីចឹងទៅនៅពេលដែលយើងជាទៅយើងទៅធ្វើការទៀតទៅ!

ក៖ គេប្រាប់យើងចឹងហ៎ម៉ា?

ខ៖ ចាស!

ក៖ ចាសម៉ា ហើយទៅកងម៉ាកងកុមារកាលនឹងកងនារីកងអីនឹងគេៗកាចដាក់ម៉ាដែរឬទេ? ឬក៏គេគិតថាម៉ាគិតថាអត់អីទេគេពេញចិត្តគេស្រលាញ់គេចេះតែអាណិតមេត្តាដល់យើងណាស់ម៉ា?

ខ៖ ចាសម៉ា
អត់អីទេរឿងកូនចៅគ្រាន់តែថាគេប្រើគ្រាន់តែអោយទៅ...កូនខ្ញុំនៅរៀងតូចៗដែរកាលនឹងនោះ!

ក៖ ចាសម៉ា!

ខ៖ គេអោយទៅកើបអាចម៏គោអីនឹងខ្ញុំចេះតែទៅៗ
ទៅរ៉ែកណ្តុររ៉ែអីចឹងទៅក៏គ្នាចេះតែទៅហើយកូនខ្ញុំនៅតូចៗណាស់កាលនឹងនោះអត់មានទាន់ចូលពួកកងគេទៅកាប់ដីកាប់អីធ្វើស្រូវធ្វើអង្ករអីអត់ដែរទេ!

ក៖ ចាសម៉ា!

ខ៖ កូនខ្ញុំវានៅតូចៗដែរណាស់!

ក៖ ហើយចុះក្រុមគ្រួសាររបស់ម៉ានៅជុំគ្នាដែរឬទេកាលននឹងម៉ា?
ដូចជាកូនរបស់ម៉ានឹងកាលនឹងនៅក្នុងតំបន់ជាមួយគ្នាឬក៏នៅបែកគ្នាដែរម៉ា?

ខ៖ កូនរបស់ខ្ញុំនៅទាំងអស់នឹងនៅជុំគ្នាទាំងអស់នឹង!

ក៖ ចាសម៉ា ចឹងបានជាម៉ាដឹងថាកូនរបស់ម៉ាមួយនឹងគេប្រើអោយធ្វើអីន៍ម៉ាន៍?

ខ៖ ចាស!

ក៖ ចាស ហើយនៅពេលនឹងកូនរបស់ម៉ាមានដែលមកលេងមកជួបនឹងម៉ាដែរឬទេ គេមានអោយសិទ្ធិមកលេងម៉ាដែរឬទេម៉ា?

ខ៖ អឺ....មានអីវាគ្រាន់តែទៅកើបអាចម៍គោមួយភ្លែតៗនឹងមួយព្រឹកៗនឹងង!

ក៖ ចាសម៉ា ហើយទៅថ្ងៃឡើងទំនេរ?

ខ៖ ដល់តែថ្ងៃទៅទំនេរចឹងទៅ
ដល់តែទំនេរចឹងទៅគេហៅទៅវ៉ៃនេះវ៉ៃនោះចឹងទៅជួនណាក៏គេប្រើអោយទៅវ៉ៃកណ្ដុរចឹងទៅ គេប្រើតែប៉ុន្នឹងទេ!

ក៖ ចាសម៉ា!

ខ៖ ព្រោះតែថាពួកវានឹងតូចៗកាលនឹងណាស់!

ក៖ ចាសម៉ាចាស ហើយទៅកូនរបស់ម៉ាប៉ុន្មាននាក់ដែលបានឆ្លងកាត់ជំនាន់អាពតនឹងម៉ា?

ខ៖ អឺម...និយាយទៅទាំងអស់ម៉ងកូនរបស់ខ្ញុំប៉ុន្មានអ្នកនឹងដូចថាបួន
ប្រាំអ្នកនឹងប៉ុន្តែគ្រាន់តែថាវានៅតូចៗនឹងណាស់មិនទាន់បានទៅធ្វើអីអត់នឹង!

ក៖ អឺម....

ខ៖ កូនប្រុសរបស់ម៉ានោះគេអោយទៅភ្ជួរដី នៅតែក្នុងស្រុកដែរអត់មានទៅណាទេ
ទាល់តែមនុស្សធំៗបានគេបញ្ជូនទៅសមរភូមិឯណោះ
ហើយយើងដូចនៅខាងក្រោយចឹងណាស់ថៅ!

ក៖ ចាសម៉ា!

ក៖ ប្រាំអ្នកនឹងធ្វើការនៅក្នុងស្រុកនឹងទៅ តែប៉ុន្នឹងទេ(សំលេងរំខានពីខាងក្រៅ)!

កៈ ចាសម៉ា
ចឹងបងប្អូនរបស់ម៉ាអត់មានស្លាប់នៅក្នុងជំនាន់ពលពតនឹងដោយសារតែគេធ្វើបាបអីអត់ទេហ៎ម៉ា?

ខៈ អត់ទេៗ!

កៈ ចាសម៉ា
ហើយម៉ាមានអ្វីដែលធ្វើអោយម៉ាចងចាំខ្លាំងជាងគេនៅក្នុងជំនាន់ពលពតនឹងណាម៉ា?

ខៈ
តែកូនរបស់ខ្ញុំទេកូនរបស់ខ្ញុំដេញគេជំលៀសទៅឆ្ងាយនឹងគ្នាស្លាប់បាត់ហើយ(កូនរបស់គាត់ដែលត្រូវគេជំលៀសទៅឆ្ងាយបានស្លាប់បាត់ហើយ)ពិបាកទាំងម្តាយទាំងកូននឹងទៅទាំងប៉ុន្មានប្អូន
ប្រាំអ្នកក៏មិនដឹងតែនៅពេលដែលត្រឡប់មកវិញរស់បានតែមួយមក(សំលេងរំខានពីខាងក្រៅ)គេអោយគ្នាទៅរស់នៅកន្លែងតំបន់ឆ្ងាយគេចែកទឹក
កន្លែងនឹងអត់ខ្លាំងហើយបានជាកូនរបស់ខ្ញុំគ្នាស្លាប់នឹង!

កៈ ចាស អើយម៉ា ហើយអឺ...គាត់អាយុប៉ុន្មានហើយម៉ាកូនរបស់ម៉ាកាលនឹងណាស់ម៉ា?

ខៈ កូនរបស់ទើបតែអាយុប៉ុន្មានអឺ....ចូល៣០ឆ្នាំហើយទេដឹងជាងសាមហើយមើលទៅ!

កៈ ចាសម៉ា!

ខៈ ហើយឥលូវនឹងនៅសល់តែចៅមួយទេនឹង គេមានកូនមានចៅរបស់គេនឹងបានបី បួន ប្រាំអ្នកទៀតទៅហើយ!

កៈ ចាសម៉ា(សំលេងរំខានពីខាងក្រៅ)!

ខៈ ហើយគ្នាកំសត់កម្រកូនណាស់ វាទៅឆ្ងាយ!

កៈ ចាសម៉ា!

ខៈ អត់បាយអត់ទឹក(សំលេងរំខានពីខាងក្រៅ)
រកអោយកូនស៊ីជូនណាទៅក៏ស្លាប់ទាំងអស់គ្នាចឹងទៅ!

កៈ ចាសម៉ា
ហើយអឺ...ម៉ានៅពេលដែលម៉ាដាច់ពីអាពតនឹងមកម៉ាធ្វើអីដែរដើម្បីចិញ្ចឹមជីវិតខ្លួនឯងណាស់ម៉ា?

ខៈ (សំលេងរំខានពីខាងក្រៅ) អឹម....ចេះតែរកនេះរកនោះទៅ
កាលនឹងគេអោយរកមង(ដាក់មងរកត្រី)រកអីនឹង រកមិនចូលក្នុងក្រុមសាមគ្គីទេ
កាលនឹងយើងបានបែកពីអាពតហើយៗអ្នកណាមានអីរកនឹងទៅណាស់ចៅ
ទិញអីៗយកមកលក់ដូរអញ្ចឹងទៅ ទិញល្មុតទិញអីនឹងយកមកលក់ដូរមានលុយចាសឯណា
ទិញល្មុតទៅទិញទៀនធុបទៅយកទៅលក់ទៅដូរអោយគេចឹងទៅគ្រាន់បាននឹងចិញ្ចឹមពោះទៅ តិចៗមករហូតដល់ឥលូវនេះហើយពិបាកណាស់ហាត់ណាស់កូនហើយ!ឪ

កៈ ចាសម៉ា
ហើយចុះម៉ាមានចងចាំអ្វីដែលម៉ាគិតថាពិបាកជាងគេនៅក្នុងជីវិតរបស់ម៉ាដែលធ្វើអោយម៉ាមិនអាចបំភ្លេចបានណាស់ម៉ា?

ខៈ ចាំនឹងចាំមិនភ្លេចទេ
ចឹងហើយបានថាចេះតែផ្តែផ្តាំកូនចៅនឹងកុំកូនវានេះ...អោយវាខិតខំប្រឹងរកប្រឹងស៊ីទៅស្រុកទេសគេសុខស្រួលហើយខំរកស៊ីទៅកុំអោយអត់កុំអោយឃ្លានចឹងទៀតណាស់នាងអើយ!

កៈ ចាសៗម៉ា....

ខៈ (ស្តាប់មិនបានលឺច្បាស់)!

កៈ ចាសម៉ា
ហើយចុះចំណែកឯអ្វីដែលម៉ាបានជួបប្រទះនៅក្នុងមួយជីវិតរបស់ម៉ាហើយវាធ្វើអោយម៉ាសប្បាយចិត្តជាងគេណាស់ម៉ាតើមានម៉ាអ្វីដែលធ្វើអោយម៉ាសប្បាយចិត្តដែរឬទេ?

ខៈ អឹម....ដូចជាសព្វថ្ងៃនឹងដូចជាសប្បាយចិត្តខ្លះៗហើយណាស់ចៅ
ដូចជាកាត់បន្ថយបានច្រើនណាស់ កាត់បន្ថយខ្លះហើយ....

កៈ រឿងអីគេទៅម៉ារឿង.....(សំលេងរំខានពីខាងក្រៅ)!

ខ៖
បើពីដើមនឹងវាចេះតែមានចែមានចុះដល់ឥលូវនឹងមានតែដូចទ្រង់រៀងរីចចំរើននៅក្នុងខ្លួនចឹង
វាធ្វើអោយយើងវាបានសប្បាយចិត្តខ្លះៗការសប្បាយចិត្តនឹងវាកាន់តែច្រើនហើយ
អត់មានកើតទុក្ខនោះទេ!

ក៖ ចាសម៉ា!

ខ៖ សព្វថ្ងៃខ្ញុំភ្លេចភ្លាំងអស់ច្រើនណាស់ បើវិញនិយាយភ្លេចមុខភ្លេចក្រោយ!

ក៖ ចាសម៉ា
ហើយអឺ....ចឹងជិវិតរបស់ម៉ាធ្លាប់មានអ្វីដែលធ្វើអោយម៉ាសប្បាយចិត្តមានហើយន៍ម៉ាន៍?

ខ៖ ចាស!

ក៖ ចាសម៉ា មានអីគេខ្លះទៅម៉ាអាចជួយប្រាប់បានឬទេ?

ខ៖ អាដែងនៃ(ភាសាតំបន់)
វាបានកូនគេរកស៊ីមានបានបន្តិចបន្តួចចឹងទៅគេចេះតែជួយផ្តល់មកដល់ខ្ញុំអីចឹងខ្លះៗចឹងមក
ណាស់គ្រាន់បានសប្បាយចិត្តនឹងគេ!

ក៖ ចាសម៉ា!

ខ៖ គ្រាន់បានចែកគ្នាបន្តិចបន្តួចនឹងទៅជូនណាទៅគេជូនលិចជូនកើតនឹងទៅណាចៅ!

ក៖ ចាសម៉ា
អឹម....ហើយម៉ាកាលពីពេលដែលម៉ានៅក្មេងៗម៉ាមានដែលធ្លាប់ស្រម៉ៃថាធំឡើងម៉ាចង់ធ្វើអីដែ
រឬទេម៉ា?

ខ៖ អឹម....មិនដឹងថាធ្វើអីទេនាងមុខរបរខ្ញុំនោះ
ម៉េចនឹងបានការងារអីធ្វើធំដុំនឹងគេបើយើងអត់ចេះអត់អីចឹងនោះ
អត់មានទេ(សំលេងរំខានពីខាងក្រៅ)
គិតតែថាចេះតែនាំគ្នារកទៅចេះតែទៅទិញអីទុកគ្រាន់លក់ដូរនឹងគេចឹងទៅចិញ្ចឹមខ្លួនចិញ្ចឹមជីវិ

តទៅត្បាញរវៃនឹងទល់នឹងសព្វថ្ងៃនឹងទៅ
កូនខ្ញុំគ្មានបានទៅធ្វើការនឹងគេឯណាអត់ផងនឹង(សំលេរំខានពីខាងក្រៅ)!

ក៖ អឺម....ចាសម៉ាចុះចឹងកាលនឹងម៉ាមានបានចូលរៀនដែរឬទេម៉ា?

ខ៖ ខ្ញុំអត់បានចូលរៀងអីនឹងគេទេនាង ឪពុកម្ដាយក្របានអីនឹងចូលរៀនសូត្រនឹងគេទេ!

ក៖
អឺម...ចាសហើយអឺ....កាលនឹងម៉ាមិនបានចូលរៀនសូត្រនឹងគេទេតែម៉ាបានអឺ...ចូលធ្វើការអី
ដែរឬទេម៉ាកាលជំនាន់មុនណាស់ម៉ា?

ខ៖ ខ្ញុំអត់បានធ្វើអីទាំងអស់នឹង(សំលេងរំខានពីខាងក្រៅ)!

ក៖ ចឹងអឺ....ម៉ាអឺ....បានធំឡើងនឹងគឺបាននៅជាមួយនឹងឪពុកម្ដាយហើយទៅគាត់ចិញ្ចឹមទៅ
ហើយបានរៀបការមានគ្រួសារហើយបានខាងលោកតាជាអ្នកចិញ្ចឹមវិញចឹងន៍ម៉ា?

ខ៖ ចាសម៉ា!

ក៖ ចាសម៉ាហើយកាលនឹង.....

ខ៖ កាលពីដើមនឹងមានបានរកអីទេកូន...ចៅហើយ
ទៅទិញតែស្វាយទិញតែផ្លែជំពូគេនឹងដើរលក់ដូរចឹងទៅកាលនឹងណាស់
ហើយសុទ្ធតែចែវទូកទៀតណាស់កាលនឹងមិនទៅមានកាណូតឯណាបើកដូ
ចយើងសព្វថ្ងៃនេះ!

ក៖ ចាសម៉ា!

ខ៖ ចែវទូក ចែវក្បូននឹងទៅទិញអីៗនឹងដោលទៅតាមព្រែកនឹងទៅ
ពីដើមមិនទៅមានកាណូតឯណាសំប្បូហូរហៀរដូចយើងឥលូវនេះ!

ក៖ ចាសម៉ាចាស
អឺម....ចឹងអឺ....ម៉ាជាចុងក្រោយតើម៉ាមានពាក្យជេចជ៍អីដើម្បីផ្ដាំផ្ញើរទៅដល់ក្មេងហើយនឹងអឺ...
អ្នកដែលគេបានស្ដាប់សំលេងរបស់ម៉ាពីពង្សប្រវត្តិហើយនឹងជីវៈប្រវត្តិរបស់ម៉ាហើយនឹងការត

ស្វូនៅក្នុងជីវិតរបស់ម៉ាតាំងពីមុនរហូរមកដល់ឥលូវនឹងតើម៉ាមានពាក្យពេចជ៍អីដើម្បីផ្ដាំផ្ញើរទៅដល់កូនចៅជំនាន់ក្រោយដែរឬទេ?

ខ៖ ផ្ដាំអោយថាខំប្រឹងធ្វើប្រឹងរកចឹងទៅចិញ្ចឹមខ្លួន(សំលេងរំខានពីខាងក្រៅ) កុំអោយពិបាកវេទនាដល់តែថាយើងវាមានបានទៅដូចថាវាសប្បាយចិត្តសប្បាយថ្លើមចឹងទៅអោយកូនចៅជំនាន់ក្រោយនឹងអោយខិតខំប្រឹងប្រែងឡើង ប្រឹងធ្វើប្រឹងរកទៅតែមានបានយើងចេះតែសប្បាយចិត្តហើយតែអត់នឹងមិនដឹងថាសប្បាយជាអីទេ វាអត់សប្បាយកើតទុក្ខវិញ!

ក៖ ចាសម៉ា!

ខ៖ ចឹងណាស់បានថាសព្វថ្ងៃនឹងចេះតែព្រួយៗនឹងនិយាយមិនចង់ចេញទេ!

ក៖ ចាសម៉ា!

ខ៖ យើងវាអត់មានមុខរបរអីធំដុំរកស៊ីនឹងគេយើងវាកំប៉ិកកំប៉ុកនឹងចេះតែខំប្រឹងរកទៅបន្តិចបន្តួចនឹងយើងចេះតែផ្សៃផ្សុំគ្នាចឹងទៅ អោយតែបានរស់ទៅនៅនឹងទៅ!

ក៖ ចាសម៉ា ចាសចឹងម៉ាមានជាពាក្យពេចជ៍អ្វីចង់ផ្ដែផ្ដាំបន្ថែមដែរឬទេម៉ា? ម៉ាមានពាក្យជាចុងក្រោយដែរឬទេម៉ា?

ខ៖ អត់មានពាក្យពេចជ៍អីសំរាប់ផ្ដាំផ្ដាំទៀតទេចៅអស់ហើយ!

ក៖ ចាសម៉ា ចឹងជាចុងក្រោយអរគុណច្រើនម៉ាជំរាបលា!

ខ៖ ចាស!